

អំណោយទាននៃការដេកលក់



(13)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ទូលបង្គំនឹងសម្រាកកាយ
> ហើយដេកលក់ទៅដោយសេចក្តីសូប
> ត្បិតឱព្រះយេហូវ៉ាអើយមានតែទ្រង់ទេដែលប្រោសឲ្យទូលបង្គំនៅដោយសាន្តត្រាណបាន។ [ទំនុកតម្កើង ៤:៨]

មានការបើកសម្តែងមួយដ៏អស្ចារ្យពីបទគម្ពីរ គឺនេះគឺជាការដេកលក់
ដែលការដេកលក់គឺជាអំណោយទានរបស់ព្រះសម្រាប់មនុស្សជាទីស្រឡាញ់របស់ទ្រង់។ ហេតុដូច្នេះហើយបានជាដាវីឌអាចនិយាយថា
នៅចំពេលមានសម្ពាធ និងសង្គ្រាម
និងមានអ្វីៗដែលនឹងកើតឡើងយ៉ាងអាក្រក់នៅជុំវិញគាត់៖

> «ទូលបង្គំនឹងសម្រាកកាយ
> ហើយដេកលក់ទៅដោយសេចក្តីសូប»។

ហេតុអ្វី? ពីព្រោះសុវត្ថិភាពរបស់គាត់ បានពឹងផ្អែកលើព្រះម្ចាស់។
មិនមែនពឹងផ្អែកលើស្ថានភាព មិនមែនលើកាល:ទេស:
មិនមែនលើសេចក្តីសន្យារបស់មនុស្សទេ
តែលើការសន្យាដែលមិនប្រែប្រួលនៃព្រះបន្ទូលរបស់ព្រះវិញ។
ស្តេចដាវីឌបាននិយាយថា៖

> «ត្បិតឱ ព្រះយេហូវ៉ាអើយ
> មានតែទ្រង់ទេដែលប្រោសឲ្យទូលបង្គំនៅដោយសាន្តត្រាណបាន»។

ដោយសុវត្ថិភាព (សេចក្តីសូប) និងដោយសន្តិភាព (សាន្តត្រាណ)។
ហេតុនេះហើយបានជាពេលយប់មកដល់ ស្តេចដាវីឌដេកលក់
ហើយស្តេចបានដឹងថាស្តេចនឹងដេកលក់ដោយសុខសាន្តត្រាណ។

មានមនុស្សច្រើនណាស់សព្វថ្ងៃនេះដែលពួកគេគ្មានការធានាដ៏មានពរបែបដូច្នេះ។ នៅពេលយប់មកដល់ ពួកគេបានប្រែចុះខ្លួនប្រែឡើង
ពួកគេមានការព្រួយបារម្ភ ពួកគេមានសេចក្តីតានតឹងចិត្ត
ហើយពួកគេភ័យខ្លាច ពួកគេមានការភាន់ភាំង។
ការព្រួយបារម្ភនិងការខ្វល់ខ្វាយនៅថ្ងៃនេះតាមដល់ពួកគេនៅពេលយប់។ ហេតុអ្វីបានជាមិនយកមេរៀនពីដាវីឌ?
ហេតុអ្វីបានជាមិនដឹងថាសុវត្ថិភាព
និងសន្តិភាពរបស់អ្នកអាចរកឃើញបាននៅក្នុងព្រះ
ដែលទ្រង់អាចធ្វើឲ្យអ្នកមានសុវត្ថិភាព ហើយអ្នកនឹងអាចនិយាយថា

«ខ្ញុំនឹងដេកលក់នៅដោយសុខសាន្តគ្រាណ»។
មានដំណោះស្រាយដ៏មានពរមួយសម្រាប់ការដេកមិនលក់។

: WD-WFTW-013-KHM
: 24 Feb 2026
: derekprince.com/km/resources

